**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសុខាភិបាល**

## សេចក្ដីជូនព័ត៌មានរបស់ក្រសួងសុខាភិបាល
## ស្ដីពី
## ករណីវិជ្ជមានវីរុសកូវីដ-១៩ ទី១២២ បានព្យាបាលជាសះស្បើយ និងមិនមានករណីវិជ្ជមានកូវីដ-១៩ ថ្មី នៅថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២០

ក្រសួងសុខាភិបាល សូមគោរពជម្រាបជូនសាធារណជនទាំងអស់ឲ្យបានជ្រាបពីស្ថានភាពជំងឺកូវីដ-១៩ នៅកម្ពុជា មានដូចខាងក្រោមនេះ៖

**១. ស្ថានភាពជំងឺកូវីដ-១៩ នៅទូទាំងប្រទេស ៖**

ត្រឹមម៉ោង០៧:០០ព្រឹក ថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២០ ស្ថានភាពជំងឺកូវីដ-១៩ នៅកម្ពុជា មាន៖

- **អ្នកព្យាបាលជាសះស្បើយ** សរុបមានចំនួនកើនឡើងដល់ **១២២នាក់** (ស្មើនឹង ១០០% ធៀបនឹងចំនួនអ្នកមានវីរុសកូវីដ-១៩ទាំងអស់ នៅក្នុងចំនួននេះ មានស្រី ៣៨នាក់ និងបុរស ៨៤នាក់) ដែលមានបុរសជនជាតិចិន ០១នាក់ ស្ត្រីជនជាតិចិន ០២នាក់ ស្ត្រីជនជាតិអង់គ្លេស ០៣នាក់ បុរសជនជាតិអង់គ្លេស ០២នាក់ បុរសជនជាតិអាមេរិកកាំង ០១នាក់ ស្ត្រីជនជាតិអាមេរិកកាំង ០១នាក់ បុរសជនជាតិបែលហ្ស៊ិក ០១នាក់ បុរសជនជាតិបារាំង ១៥នាក់ (ក្នុងនេះ មានទារកអាយុ ០៤ខែ) ស្ត្រីជនជាតិបារាំង ២១នាក់ បុរសជនជាតិកាណាដា ០២នាក់ បុរសជនជាតិម៉ាឡេស៊ី ១៣នាក់ បុរសជនជាតិឥណ្ឌូនេស៊ី ០២នាក់ ស្ត្រីជនជាតិវៀតណាម ០៣នាក់ បុរសជនជាតិខ្មែរ ៤៣នាក់ និងស្ត្រីជនជាតិខ្មែរ ០៨នាក់ (គិតចាប់ពីខែមករាដល់បច្ចុប្បន្ននេះ)។

*(កត់សម្គាល់៖ ក្រសួងសូមធ្វើការកែតម្រូវលេខអ្នកជាសះស្បើយជាបុរសមានចំនួនសរុប ៨៤នាក់ ដោយនៅថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២០ មានបុរសវ័យ ៧៥ឆ្នាំ នៅខេត្តកំពង់ឆ្នាំង បានព្យាបាលជាសះស្បើយ តែមិនទាន់បានបូកបញ្ចូលតួលេខ ហើយបានដាក់ចេញផ្សាយជាបន្តបន្ទាប់ពីថ្ងៃនោះមកហូតដល់ថ្ងៃម្សិលមិញនេះ)។*

- មិនមានអ្នកជំងឺកូវីដ-១៩ ដែលកំពុងសម្រាកព្យាបាលទៀតឡើយ នៅទូទាំងប្រទេស
- អ្នកមានវីរុសកូវីដ-១៩ ដែលបានរកឃើញទាំងអស់ នៅទូទាំងប្រទេសសរុបចំនួន ១២២នាក់ (ស្ត្រី ៣៨នាក់ និងបុរស ៨៤នាក់)។

**២. ករណីវិជ្ជមានវីរុសកូវីដ-១៩ទី១២២ បានព្យាបាលជាសះស្បើយ ៖**

- ស្ត្រីជនជាតិខ្មែរ អាយុ ៣៦ឆ្នាំ រស់នៅភូមិប៉ាលេឡៃ សង្កាត់ផ្សារកណ្ដាល ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ត្រូវបានឯកឧត្តមសាស្ត្រាចារ្យ ម៉ម ប៊ុនហេង រដ្ឋមន្ត្រីក្រសួងសុខាភិបាល សម្រេចបញ្ជូនមកសម្រាកព្យាបាលបន្តនៅមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត នាថ្ងៃទី០៨ ឧសភា ឆ្នាំ២០២០ នោះ បច្ចុប្បន្នត្រូវ

បានព្យាបាលជាសះស្បើយដោយទទួលបានលទ្ធផលតេស្ត អវិជ្ជមានវីរុសកូវីដ-១៩ ចំនួន ០២ដង ហើយត្រូវបានអនុញ្ញាតអោយចេញពីពេទ្យមិត្តភាពខ្មែរ-សូវៀត។ ស្ត្រីរូបនេះ ជាករណីជំងឺកូវីដ-១៩ ទី១២២ នៅក្នុងប្រទេសកម្ពុជា ដែលត្រូវបានក្រុមគ្រូពេទ្យនៃមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត បានព្យាបាលជាសះស្បើយ ដែលធ្វើឲ្យចំនួនអ្នកព្យាបាលបានជាសះស្បើយកើនបាន ១00% ហើយមិនមានអ្នកស្លាប់ដោយសារជំងឺកូវីដ-១៩ នេះឡើយ។ ដើម្បីជាការលើកទឹកចិត្ត ក្រសួងសុខាភិបាល សូមអបអរសាទរដល់ស្ត្រីរូបនេះ ដែលបានព្យាបាលជាសះស្បើយ ហើយក៏សូមសម្តែងនូវក្តីសោមនស្សរីករាយ និងអំណរសាទរជូនពរយ៉ាងកក់ក្តៅពក់ទាក់ ចំពោះស្ត្រីដែលជាករណីជំងឺកូវីដ-១៩ ទី១២២ នេះផងដែរ។

**៣. មិនមានករណីវិជ្ជមានវីរុសកូវីដ-១៩ ថ្មី ឡើយ** នៅថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២០។

**៤. ចំនួនសរុបវត្ថុសំណាកដែលបានធ្វើវិភាគ** ទាំងអស់មានចំនួន ១៤,៦៨៤ សំណាក សម្រាប់ទូទាំងប្រទេស (គិតចាប់តាំងពីខែមករា ឆ្នាំ២០២០ មកដល់ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២០) ដែលក្នុងចំណោមប្រជាជនមួយលាននាក់ កម្ពុជាបានធ្វើវិភាគបានចំនួន ៩០៣សំណាក ដែលជាចំនួនច្រើនជាងបណ្តាប្រទេសមួយចំនួននៅក្នុងតំបន់អាស៊ានយើងនេះ។

**៥. សារអំពាវនាវសំខាន់ៗ៖**

សូមរំលឹកសារជាថ្មីម្តងទៀតថា ដើម្បីបន្តរក្សានូវកិច្ចការពារកុំឲ្យមានរលកទីពីរនៃការចម្លងវីរុសកូវីដ-១៩ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ឯកឧត្តមសាស្ត្រាចារ្យ **ម៉ម ប៊ុនហេង** រដ្ឋមន្ត្រីក្រសួងសុខាភិបាល បានធ្វើការក្រើនរំលឹក និងបន្តអំពាវនាវដល់បងប្អូនប្រជាពលរដ្ឋទាំងអស់ឲ្យចូលរួមអនុវត្តន៍វិធានការការពារខ្លួន បើទោះបីជាប្រទេសកម្ពុជា មិនមានរកឃើញករណីជំងឺកូវីដ-១៩ ថ្មី ក្នុងរយៈពេលជាងមួយខែកន្លងមកនេះក្តី ហើយករណីជំងឺកូវីដ-១៩ ទី១២២ បានព្យាបាលជាសះស្បើយហើយក៏ដោយ ក៏យើងនៅមានកិច្ចការជាច្រើនទៀតដែលត្រូវអនុវត្តន៍ជាបន្តបន្ទាប់ ជាពិសេសការត្រួតពិនិត្យដោយហ្មត់ចត់នូវសុខភាពអ្នកដំណើរដែលចូលមកក្នុងប្រទេសកម្ពុជាដើម្បីចៀសវាងការនាំចូលនូវវីរុសកូវីដ-១៩ ហើយបុគ្គលគ្រប់រូប ក៏ត្រូវតែមានការប្រុងប្រយ័ត្ន និងអនុវត្តវិធានការការពារការចម្លងឲ្យបានជាប់ជានិច្ច ដោយត្រូវចេះកែប្រែទម្លាប់ និងឥរិយាបទនៃការរស់នៅរបស់ខ្លួនឲ្យស្របទៅតាម "*សភាពធម្មតាតាមបែបគន្លងថ្មី (New Normal Life) ក្នុងបរិបទប្រយុទ្ធនឹងជំងឺកូវីដ-១៩*" ជាចាំបាច់ ដូចជាការប្រកាន់យកនូវការអនុវត្តអនាម័យដៃស្អាត ពាក់ម៉ាស់ (ក្នុងករណីចាំបាច់) ប្រើក្រម៉ាកន្សែង ឬក្រដាសជូតមាត់ ខ្ទប់មាត់ពេលមានក្អកកណ្តាស់ បន្តអនុវត្តន៍គម្លាតសុវត្ថិភាពសង្គម និងគម្លាតសុវត្ថិភាពបុគ្គល មិនត្រូវមានការជួបជុំ ឬរៀបចំពិធីណាមួយដែលមានគ្នាច្រើនកុះករពេក ដូចជាការជួបជុំស៊ីផឹកដែលមានគ្នាច្រើន ឬការជួបជុំតាមបែបសាសនា ជាដើម ។ ម្ចាស់ភោជនីយដ្ឋាន និងអាហារដ្ឋាន ព្រមទាំងកន្លែងលក់ដូរផ្សេងៗ ត្រូវតែបន្តអនុវត្តន៍វិធានការការពារឲ្យទៅតាមបែបនៃការរស់នៅ "*សភាពធម្មតាតាមបែបគន្លងថ្មី ក្នុងបរិបទប្រយុទ្ធនឹងជំងឺកូវីដ-១៩*" នៅកម្ពុជា ដូចបានជម្រាបជូនខាងលើនេះស្រាប់ ប្រកបដោយការទទួលខុសត្រូវខ្ពស់ និងត្រូវធានាថា ទីតាំងធុរកិច្ចរបស់ខ្លួនមិនត្រូវក្លាយជាទីកន្លែងចម្លងវីរុស កូវីដ-១៩ ដល់អតិថិជន ឬអ្នកបម្រើការនៅទីនោះឡើយ។ បុគ្គលគ្រប់រូប មិនត្រូវភ្លេចខ្លួនថា វីរុសកូវីដ-១៩ អាចចម្លងមកមនុស្សបានគ្រប់

ពេលវេលា គ្រប់កាលៈទេសៈ និងគ្រប់ទីកន្លែង ហើយការប្រយុទ្ធនឹងជំងឺកូវីដ-១៩ កុំឲ្យកើតមានលើបុគ្គល និងសហគមន៍យើងនេះ នៅតែត្រូវខិតខំធ្វើជាបន្តទៀតនៅឡើយ ហើយនៅពេលខាងមុខនេះ នឹងអាចមានករណីវិជ្ជមានមានវីរុសនេះ ប្រសិនបើយើងមានការធ្វេសប្រហែស មិនបានការពារខ្លួនតាមការណែនាំរបស់ប្រមុខរាជរដ្ឋាភិបាល និងរបស់ក្រសួងសុខាភិបាល។

លើសពីនេះ ឯកឧត្តមសាស្ត្រាចារ្យរដ្ឋមន្ត្រីក្រសួងសុខាភិបាល ក៏បានធ្វើការណែនាំដល់មន្ទីរសុខាភិបាលរាជធានី-ខេត្តទាំងអស់ ព្រមទាំងបុគ្គលិក-មន្ត្រីសុខាភិបាល ជាពិសេសក្រុមគ្រូពេទ្យនៅគ្រប់លំដាប់ថ្នាក់ (ទាំងថ្នាក់ជាតិ និងក្រោមជាតិ) ឲ្យយកចិត្តទុកដាក់ បន្តការផ្តល់ការថែទាំ និងព្យាបាលអ្នកជំងឺផ្សេងៗទៀត ទន្ទឹមគ្នាទៅនឹងការយកចិត្តទុកដាក់ផ្តល់សេវាពិនិត្យព្យាបាលអ្នកជំងឺកូវីដ-១៩ ហើយត្រូវបង្កើនការយកចិត្តទុកដាក់ និងបន្តការងារផ្តល់សេវាសុខាភិបាលនានា ដូចជាសកម្មភាពផ្តល់សេវាសុខភាពមាតា កុមារ និងទារក ការងារចាក់ថ្នាំបង្ការ កិច្ចការពារជំងឺគ្រុនឈាម ការងារប្រយុទ្ធប្រឆាំងទៅនឹងជំងឺគ្រុនចាញ់ អេដស៍ និងរបេង ដែលកម្មវិធីគ្រុនចាញ់នេះទាមទារនូវការខិតខំរួមគ្នាថែមទៀតដើម្បីឆ្ពោះទៅរកការលុបបំបាត់ជំងឺនេះទាំងស្រុង ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ដែលបានដាក់ចេញឲ្យអនុវត្តន៍ដោយ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ដោយមិនត្រូវឲ្យមានការអាក់ខាន ឬរាំងស្ទះដំណើរការផ្តល់សេវាសុខាភិបាលណាមួយ ដោយសារតែជំងឺកូវីដ-១៩ នេះឡើយ។

## ៦. ការផ្អាកមិនធ្វើសន្និសីទសារព័ត៌មាន និងផ្អាកការចេញផ្សាយសេចក្តីជូនព័ត៌មាន ចាប់ពីថ្ងៃអាទិត្យ ទី១៧ ខែឧសភា ឆ្នាំ២០២០ ៖

ក្រសួងសូមជម្រាបជូនសាធារណជនទាំងអស់ឲ្យបានជ្រាបថា ការចេញផ្សាយសេចក្តីជូនព័តមានប្រចាំថ្ងៃ និងការធ្វើសន្និសីទសារព័ត៌មានប្រចាំសប្តាហ៍ ត្រូវបានផ្អាកធ្វើជាបណ្តោះអាសន្ន ចាប់ពីថ្ងៃអាទិត្យ ទី១៧ ខែឧសភា ឆ្នាំ២០២០ នេះតទៅ។ នៅពេលខាងមុខនេះ ប្រសិនបើមានរកឃើញករណីវិជ្ជមានកូវីដ-១៩ថ្មី ឬការវិវត្តន៍ថ្មីពាក់ព័ន្ធនឹងស្ថានភាពជំងឺកូវីដ-១៩ នៅកម្ពុជា ក្រសួង នឹងជម្រាបជូនដំណឹងជូនសាធារណជនទាំងអស់ឲ្យបានជ្រាបជាមិនខានឡើយ។ ក្រសួងសុខាភិបាល សូមបញ្ជាក់ជូនថា ការផ្អាកជូនព័ត៌មាន និងការផ្អាកធ្វើសន្និសីទសារព័ត៌មាននេះ មិនមែនជាការបង្ហាញពីការចម្លងវីរុសកូវីដ-១៩ នៅកម្ពុជា ត្រូវបានបញ្ចប់ជាស្ថាពរនោះឡើយ។ ថ្វីត្បិតតែករណីជំងឺកូវីដ-១៩ ទី១២២ បានព្យាបាលជាសះស្បើយ និងមិនមានការរកឃើញករណីវិជ្ជមានវីរុសកូវីដ-១៩ ថ្មី ក៏ពិតមែន តែហានិភ័យនៃការចម្លងវីរុសកូវីដ-១៩ នេះ នៅតែមានចំពោះមុខយើងទាំងអស់គ្នានៅឡើយទេ ល្អិតណាសាកលលោក និងប្រទេសជិតខាងក្នុងតំបន់ នៅតែមានកំណើននៃករណីឆ្លងថ្មី ប្រទេសកម្ពុជា នៅតែប្រឈមទៅនឹងហានិភ័យនៃការចម្លងជំងឺកូវីដ-១៩។ ដូច្នេះហើយបុគ្គលគ្រប់រូបត្រូវតែបន្តការប្រុងប្រយ័ត្ន និងតាមដានសុខភាពផ្ទាល់ខ្លួនជាចាំបាច់ ជាពិសេសបងប្អូនដែលចល័ត ឬធ្វើបម្លាស់ទីនៅតាមច្រកចេញ-ចូលអន្តរជាតិ និងច្រករបៀង ឬតាមព្រំដែននានា ដែលត្រូវតែអនុវត្តន៍ប្រកាន់ខ្ជាប់នូវវិធានការការពារ

ចាំបាច់ ដើម្បីសុខភាពផ្ទាល់ខ្លួន មិនមានវីរុសកូវីដ-១៩ និងជំងឺឆ្លងផ្សេងៗទៀត។

**៧. ការថ្លែងអំណរគុណ៖**

ក្រសួងសុខាភិបាល សូមគោរពដឹងគុណដ៏ខ្ពង់ខ្ពស់មិនអាចបំភ្លេចបាន និងសូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជាទីបំផុតជូនចំពោះ: **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ដែលបានយកចិត្តទុកដាក់ដឹកនាំចង្អុលបង្ហាញដល់ក្រសួងសុខាភិបាល និងស្ថាប័ននានា ក្នុងការប្រយុទ្ធនឹងជំងឺកូវីដ-១៩ ប្រកបដោយភាពឈ្លាសវៃ និងបុរេសកម្មដោយគតិបណ្ឌិតខ្ពង់ខ្ពស់ ព្រមទាំងការផ្តួចផ្តើមចែករំលែក និងគៀងគរធនធាន សម្រាប់សកម្មភាពទប់ស្កាត់ការចម្លងវីរុសកូវីដ-១៩ ដែលមានលទ្ធផលល្អប្រសើរ និងការពារបានមិនឲ្យមានការចម្លងចូលក្នុងសហគមន៍។

ឯកឧត្តមសាស្ត្រាចារ្យ ម៉ម ប៊ុនហេង រដ្ឋមន្ត្រីក្រសួងសុខាភិបាល និងថ្នាក់ដឹកនាំ ព្រមទាំងមន្ត្រី-បុគ្គលិកសុខាភិបាលទូទាំងប្រទេស សូមលំឱនកាយគោរពជូនពរ **សម្តេចតេជោនាយករដ្ឋមន្ត្រី** និង **សម្តេចកិត្តិព្រឹទ្ធបណ្ឌិតប្រធានកាកបាទក្រហមកម្ពុជា** ព្រមទាំងបុត្រាបុត្រី ចៅប្រុសចៅស្រី និងក្រុមគ្រួសារទាំងអស់ សូមជួបប្រទះតែសុខភាពល្អបរិបូរណ៍ ដើម្បីដឹកនាំនាវាកម្ពុជាឲ្យកាន់តែរីកចម្រើនមានការអភិវឌ្ឍលឿនលឿន និងជួបតែពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ និងបដិភានៈ កុំបីឃ្លៀងឃ្លាតឡើយ។

ក្រសួងសុខាភិបាល ក៏សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជាទីបំផុតជូនដល់ថ្នាក់ដឹកនាំ មន្ត្រី-បុគ្គលិកសុខាភិបាល និងក្រុមគ្រូពេទ្យទាំងអស់នៅទូទាំងប្រទេស ស្ថាប័ន និងអាជ្ញាធរពាក់ព័ន្ធទាំងអស់ ទាំងថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ឯកឧត្តមនាយឧត្តមសេនីយ **ហ៊ុន ម៉ាណែត** និងកងកម្លាំងមានសមត្ថកិច្ចទាំងអស់ ក្រុមគ្រូពេទ្យស្ម័គ្រចិត្ត**សម្តេចតេជោ** (THIDA) កាកបាទក្រហមកម្ពុជា អង្គការសុខភាពពិភពលោក មជ្ឈមណ្ឌលគ្រប់គ្រងនិងបង្ការជំងឺសហរដ្ឋអាមេរិក វិទ្យាស្ថានប៉ាស្ទ័រកម្ពុជា ធុរកិច្ចឯកជននិងបុគ្គលស្ម័គ្រចិត្តផ្តល់ជំនួយមនុស្សធម៌នានា ដៃគូសុខាភិបាល និងបណ្តាប្រទេសជាមិត្តទាំងអស់ ដែលបានខិតខំបំពេញភារកិច្ចបានល្អប្រសើរបំផុត ក្នុងការជួយពិនិត្យសុខភាព និងស្រាវជ្រាវរកករណីកូវីដ-១៩ ព្រមទាំងអ្នកប៉ះពាល់ទាំងអស់កន្លងមក រួមទាំងការដាក់វិធានការនានា និងបានចែករំលែកនូវធនធានថវិកា និងសម្ភារៈ ជាអំណោយមនុស្សធម៌ជូនដល់ក្រសួងសុខាភិបាល ដើម្បីទប់ស្កាត់ការចម្លងវីរុសកូវីដ-១៩ នៅក្នុងប្រទេសកម្ពុជា រហូតទទួលបានលទ្ធផលល្អប្រសើរ។

ក្រសួងសុខាភិបាល បន្តជូនដំណឹងដល់សាធារណជនអំពីការវិវត្តន៍នៃបញ្ហាសុខភាព តាមទំព័រហ្វេសប៊ុក និងគេហទំព័ររបស់ក្រសួង www.cdcmoh.gov.kh ដែលគេហទំព័រនេះមានសម្ភារៈអប់រំសុខភាពដែលអាចទាញយកមកប្រើប្រាស់បាន។ សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងមកទូរស័ព្ទទាន់ហេតុការណ៍ ក្រសួងសុខាភិបាល លេខ ១១៥ ដោយឥតគិតថ្លៃ ឬទំនាក់ទំនងក្រសួងសុខាភិបាល តាមលេខទូរស័ព្ទ៖ ០១២ ៨២៥ ៤២៤ ឬ ០១២ ៤៨៨ ៩៨១ ឬ ០១២ ៨៣៦ ៨៦៨ ។

ថ្ងៃសៅរ៍ ១០រោច ខែពិសាខ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២០

វេជ្ជបណ្ឌិត **ឱ វណ្ណឌីន**

រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យក្រសួងសុខាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

# ស្ថានភាពនៃជំងឺកូវីដ-១៩ នៅកម្ពុជា

## គិតដល់ ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២០

## និន្នាការនៃចំនួនវិជ្ជមានកូវីដ-១៩ សរុបប្រចាំថ្ងៃ




ប្រភព៖ ក្រសួងសុខាភិបាល

# ស្ថានភាពនៃជំងឺកូវីដ-១៩ នៅកម្ពុជា

## គិតដល់ ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២០

## ចំនួនករណី វិជ្ជមានកូវីដ-១៩ ដែលបានរកឃើញ បែងចែកតាមសញ្ជាតិ




ប្រភព៖ ក្រសួងសុខាភិបាល

# ស្ថានភាពនៃជំងឺកូវីដ-១៩ នៅកម្ពុជា

## គិតដល់ ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២០

## ចំនួនករណី វិជ្ជមានកូវីដ-១៩ ដែលបានរកឃើញនៅតាមរាជធានីខេត្ត

## សរុប ១២២ ករណី




ប្រភព៖ ក្រសួងសុខាភិបាល

# ស្ថានភាពនៃជំងឺកូវីដ-១៩ នៅកម្ពុជា

**គិតដល់ ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២០**

**ចំនួនករណីវិជ្ជមានកូវីដ-១៩ ដែលបានរកឃើញនៅតាមរាជធានីខេត្ត**

**សរុប ១២២ ករណី**




ប្រភព៖ ក្រសួងសុខាភិបាល